រាក់កំផែល

វណ្ណី រតនា

ខ្ញុំខ្វាក់ខ្ញុំពិតជាខ្វាក់មែនម៉ាស៊ីនថតដុំហ្វីល៣៦ប៉ុសតំលៃ៨អឺរ៉ូនិងកែវ(ម៉ាស៊ីនថត)យើងទាំងអស់គ្នាសុទ្ធតែខ្វាក់មើលមិនឃើញខ្ញុំមិនដឹងថាតើមានពណ៌ព្រោងព្រៀតទាំងខាងក្នុងនិងខាងក្រៅយ៉ាងណានោះទេឬមួយខ្ញុំឃើញការពិតជាក់ស្តែងមួយពេលមួយនោះខ្ញុំនៅលើដងផ្លូវជាមួយម៉ាស៊ីនថតខ្វាក់របស់ខ្ញុំប្រហែលជាខ្ញុំឃើញនារីពីរនាក់ប្រហែលជាពួកគេកំពុងរងចាំមិត្តប្រុសដែលពួកគេទើបរកឃើញថ្មីៗមិត្តប្រុសទាំងពីរនាក់នោះមានឆ្កែខ្វាក់ពីរក្បាលលូលូដឺប៉ូម៉េរ៉ានីស៍ហើយបុរសទាំងពីរនាក់ក៏ខ្វាក់បុរសទាំងពីរជិះឡានមករកនាងហើយជាធម្មតាពួកគេចតឡាននៅលើទីដីដ៏ធំល្វឹងល្វើយមួយគ្មានកោះត្រើយឡាននោះក៏ខ្វាក់ដូចម៉ាស៊ីនថតរបស់ខ្ញុំខ្ញុំក៏ខ្វាក់វរជនការទូតដែលមានជីវភាពធូរធារកំពុងនាំគ្នាឈរស្តាប់មនុស្សអនាមិកម្នាក់ដែលនិយាយត្រឡប់ត្រឡិនដូចមនុស្សខ្វាក់អំពីរឿងរ៉ាវនៃពិពណ៌រូបថតមួយពាក្យពេចន៍ដែលគាត់និយាយចេញមកសុទ្ធតែខ្វាក់សម្លេងនិយាយចេញមកក៏ខ្វាក់ហើយខ្ញុំក៏ខ្វាក់ដូចម៉ាស៊ីនថតនិងដុំហ្វីលរបស់ខ្ញុំដែររ៉ូបក្រហមឆើតរបស់កញ្ញាសក់សប្បុរទង់ដែងក៏ខ្វាក់ទៅទៀតច្បាស់ហើយនាងពិតជាមិនមើលមិនឃើញពណ៌រ៉ូបរបស់នាងឡើយសម្លេងស្បែកជើងកែងចោទរបស់កញ្ញាអ្នករដ្ឋធានីប៉ារីស៍រងារបើកមាត់លែងរួចស្បែកជើងនៅស្ងៀមឆ្កឹងហើយសុទ្ធតែខ្វាក់ទាំងអស់តែម្តងខ្ញុំឥតដឹងទាល់តែសោះថាមានស្នាមទឹកនោមនៅក្នុងស្ថានីយ៍ម៉េត្រូម៉ាល់ស្បែរបស៍នៅសង្កាត់ទី១៧មុខជានរណាម្នាក់ដើរជាន់ទឹកនោមនោះហើយមើលទៅឬក៏អ្នកនោះជាន់ទឹកនោមខ្លួនឯងបើអញ្ជឹងគាត់ពិតជាខ្វាក់នៅក្នុងរូងផ្លូវដ៏ងងឹតនាម៉េត្រូក្រុងប៉ារីស៍ជាមិនខានដៃគូរស្នេហាដ៏សុខសប្បាយមួយគូរចូលចិត្តប្រលោមស្នេហ៍និងជុះនោមក្នុងរូងផ្លូវដ៏ងងឹតនាស្ថានីយ៍ម៉េត្រូជាទីដែលបង្ហាញទិដ្ឋភាពពិតប្រាកដនៃជីវិតអ្នកក្រុងប៉ារីស៍ដែលរាល់សេចក្តីស្លាប់មិនមានភក្តីភាពបន្តិចណាទាល់តែសោះទៅលើរូបពួកគេហើយពួកអ្នកក្រុងប៉ារីស៍ទាំងនោះក៏គ្មានភក្តីភាពបន្តិចណាឡើយចំពោះសេចក្តីស្លាប់របស់ខ្លួនគេផ្ទាល់ដែរគេខ្វាក់ទាំងអស់គ្នាខ្ញុំមានអារម្មណ៍ថានៅឯប័រស្តុងសុងអាកាសធាតុត្រជាក់ខ្លាំងណាស់ដើមឈើទន្លេបឹងបួរផ្ទះសំបែងឈរភ័យរងារឥតកក្កមាហើយព្រមទាំងខ្វាក់មើលមិនឃើញទាំងអស់គ្នាទៀតទាំងសត្វស្លាបស៊ីហ្គូញក៏នៅនឹងថ្កល់ហើយខ្វាក់ទាំងអស់តែពួកវាអាចហោះហើរដូចសត្វព្រាបដែរនៅក្នុងទីខ្វាក់ល្ងឹតសូន្យសុងទៅតាមខ្សែរលកវាយោនៃទឹកដីនៃប្រទេសបារាំងហើយខ្សែវាយោដ៏វែងអន្លាយសុទ្ធតែខ្វាក់ល្ងឹតល្ងល់ទៅទៀតវាយោខ្លួនឯងក៏ខ្វាក់ពួកគេទាំងនោះមើលមិនឃើញគ្នាទៅវិញទៅមកទេមើលឃើញថាមានកង់មួយបានដេកស្លាប់ក្នុងប្រឡាយទឹកស្អុយមួយនាខែត្រអាល់ស្សាសស៍វាខ្វាក់វាមើលមិនឃើញផ្លូវលំនៅចំកណ្តាលថ្ងៃត្រង់ក្តៅស្ទើរបែកក្បាលព្រះសុរិយាក៏ខ្វាក់យកមួយអស់ដៃហើយខ្ញុំក៏ខ្វាក់យកអស់តែមួយទម្ងឹងគ្មាននរណាម្នាក់ចេញមកបិទភ្លើងហាងលក់ក្រែបឡើយអញ្ជឹងហើយភ្លើងបើកចោលទទេពីព្រោះអ្នកទាំងនោះខ្វាក់ទាំងអស់ហើយក៏គ្មាននរណាម្នាក់បានចាំពណ៌ភ្លើងហាងលក់ក្រែបនោះដែរខ្ញុំក៏មិនអាចចាំបានដែរហ៊ឹច្បាស់ជាមាននរណាម្នាក់បោះផ្កាចោលលើដីមើលទៅផ្កានោះពិតជាស្អាតតែម្តងប៉ុន្តែស្តាយណាស់ដែលផ្កានោះមិនអាចមើលឃើញពណ៌របស់ខ្លួនដូចនារីអ្នកក្រុងប៉ារីស៍ដ៏គួរអោយខ្នាញ់កំពុងឈរចាំរថភ្លើងនាក្រោមដីនាងទាំងនោះស្លៀកពាក់មានពណ៌ល្អឆើតឆាយពេកក្រៃស្តាយណាស់លោកអើយពួកនាងមិនអាចមើលឃើញពណ៌ដ៏ស្រស់បំព្រងនោះទេខ្វាក់ទាំងស្រុងពួកនាងពិតជាខ្វាក់ខ្ញុំក៏ខ្វាក់យកតែមែនទែនខ្មើយភ្លួយដើមឈើងាប់នាងកញ្ញាដែលកំពុងឈររងចាំកូនឆ្កែដ៏ប្រសេចប្រសាចរបស់នាងមុខជាល្ងឹតខ្វាក់នៅពេលដែលអរុណរស្មីចាប់បដិសន្ធិឡើងក្រោយពីមរណភាពដ៏កប់លុងជ្រៅមួយនៅក្នុងទីងងឹតសូន្យសុងហៅមិនឮរាត្រីកាលចូលមកដល់ហើយស្បែងងឹតនៃរាត្រីនោះក៏ខ្វាក់ហើយខ្វាក់នោះខ្វាក់ជនជាតិអារ៉ាប់បង្ហុយបារីហើយលាក់មុខរបស់ខ្លួននៅក្នុងទីអាថ៌កំបាំងគាត់មិនអាចមើលឃើញពិភពលោកនៅជុំវិញខ្លួនគាត់បន្តិចណាសោះគាត់ខ្វាក់គាត់អាចភ្លក់រសជាតិនៃស្រាបៀបារីរបស់គាត់ក្តៅសែនក្តៅហើយខ្វាក់បុរសនោះលង់លក់នៅក្នុងសេចក្តីស្លាប់បាត់ទៅហើយសពរបស់គាត់បានតម្កល់ទុកនាឯសារៈមន្ទីរបុរសនោះខ្វាក់មរណភាពរបស់គាត់ក៏ខ្វាក់មើលទៅសេចក្តីស្លាប់របស់ខ្ញុំក៏ខ្វាក់ដោយគ្មានមូលហេតុផងដែរក៏មិនដឹងដូចក្តីមរណារបស់សត្វស្លាបករវែងដែលតាំងខ្លួនដូចជាកំពុងនៅរស់នាសារៈមន្ទីរដដែលដោយគេដាក់អោយនៅក្នុងកញ្ចក់ហ៊ុមព័ទ្ធទៅដោយភាពល្ងឹតសូន្យសុងនិងភាពស្ងៀមស្ងាត់ភាពស្ងៀមស្ងាត់ក៏ខ្វាក់សូន្យសុងទៅទៀតហើយខ្ញុំក៏ខ្វាក់តារតុនអត់ដឹងទាល់តែសោះថាពិភពលោកពិតជាមានវាបានកើតហើយឥឡូវចាស់ទៅៗដើម្បីរងចាំសេចក្តីស្លាប់ម្យ៉ាងដែរវាមើលមិនឃើញក្តីមរណារបស់វាទាល់តែសោះវាខ្វាក់តែម្តងដោយឥតសង្ស័យក្តីមរណារបស់វាក៏ខ្វាក់ហួសនិស្ស័យទៅទៀតម្ចាស់វាសួរប្រសិនបើវាចង់ចេញទៅមើលដើមឈើនៅទីសាធារណៈស័រប៊ិនន៏ជាទីដែលវាតែងតែបាញ់នោមហើយជុះអាចម៍នៅម៉ោង១០ល្ងាចកំឡុងពេលដែលមនុស្សម្នាទាំងឡាយកំពុងទទួលទានអាហារហើយនិយាយគ្នាលេងទាំងខ្វាក់ឡប់សតិប៉ុន្តែតារតុនបដិសេធដាច់អហំការថាមិនទៅទីនោះពីព្រោះវាមានអារម្មណ៍ថាទើបកំពុងទទួលបានពន្លឺពីភ្លើងអំពូលម៉ែត្រនៅក្នុងអាងងូតទឹកនាផ្ទះល្វែងពណ៌សតូចមួយនាសង្កាត់ទី៥ជាទីដែលតារតុនបានកើតហើយឥឡូវកំពុងរងចាំមរណាឬប្រហែលជាវាមិនស្លាប់នៅផ្ទះល្វែងនោះទេមើលទៅសេចក្តីស្លាប់គឺខ្វាក់ទាំងស្រុងស្រណោះណាស់ដៃគូរស្នេហាដ៏ខ្ចីល្ងក់ត្រូវតែនាំគ្នារត់ចេញអោយឆ្ងាយពីសាសនាដ៏ល្ងិតល្ងង់និងដ៏ច្រើនមហិមាដោយជិះម៉ូតូពណ៌ខៀវដែលជាអំណោយពីឪពុកម្តាយរបស់នារីជំទង់ក្មេងខ្ចីសំរាប់ខួបកំណើតទី១៨របស់នាងនាងអត់ចេះបើកបរម៉ូតូនោះទេនាងខ្វាក់ល្ងឹតស្លុបតែម្តងបន្ទាប់ពីចប់ថ្ងៃបុណ្យខួបកំណើតទី១៨ឆ្នាំរបស់នាងភ្លាមសង្សារប្រុសរបស់នាងមុខជានិងខ្វាក់ក្នុងរយៈពេលពីរទៅបីម៉ោងខាងមុខនេះដូច្នេះហើយបុរសនោះខំបើកភ្នែកធំៗអស់ៗហើយខំបើកម៉ូតូទៅមុខយ៉ាងលឿនក្រៃលែងដូចផ្លេកបន្ទោរនារីខ្ចីល្ងក់អង្គុយអោបចង្កេះពីក្រោយស្តាយណាស់បុរសយើងនិងធ្លាក់ខ្លួនពិការនៅតាមដងផ្លូវក្ងិក្ងក់តូចចង្អៀតនោះទាំងពីរនាក់និងបើកបរទៅកាន់ទីល្ហួរល្ហេវគ្មានទិសដៅទីគ្មានទិសដៅដែលសេរីភាពដ៏ខ្វាក់ងងឹតស្លុបត្រូវតែសុំជ្រកមមកជាមួយដោយគ្មានអនុសញ្ញាប្រពៃណីឬទំនៀមទម្លាប់អ្វីទាំងអស់